# បច្ចេកទេសបំប៉នកូនត្រី

## ត្រីទីឡាព្យ៉ា ត្រីឆ្ពិន
## ត្រីកាបសាមញ្ញ និងត្រីកាបស



# សេចក្តីផ្តើម

ការចញ្ចឹមត្រីជាផ្នែកមួយយ៉ាងសំខាន ក្នុងវិស័យកសិកម្ម ដែលផ្តល់ប្រយោជន៏ច្រើន ដល់ការបម្រើជីវភាពផ្នែកម្ហូបអាហាររបស់ប្រជារាស្ត្រ ពិសេសប្រជាកសិករក្រីក្រដែលរស់នៅឆ្ងាយពីដែននេសាទដូចជាៈឡូត៍នេសាទ-ទន្លេ-បឹង-ព្រែក ឬ តំបន់ទឹកធម្មជាតិនានា។ ដើម្បីបំពេញគោលបំណង់សំខាន់ និងចាំបាច់នេះ រដ្ឋបាលជលផលបាននិងកំពុងយកចិត្តទុកដាក់ជំរុញផ្នែកចិញ្ចឹមត្រីនេះឱ្យមានការអភិវឌ្ឍន៏ដល់តំបន់ជាច្រើនដែលខ្សត់ត្រី នៅក្នុងបណ្តាលខេត្តមួយចំនួននៃព្រះរាជជាណាចក្រកម្ពុជា ដោយបញ្ជូនអ្នកជំនាញបច្ចេកទេសផ្នែកចិញ្ចឹមត្រី ចុះជួយបង្ហាត់បង្រៀនកសិករឱ្យចេះរប្រៀបចញ្ចឹមត្រី និងរៀបចំគ្រប់គ្រងអភិវឌ្ឍន៏ការចិញ្ចឹមត្រីឱ្យបានល្អ ដើម្បីជួយដោះស្រាយជីវភាពផ្នែកម្ហូបអាហាររបស់គាត់។

ដោយយល់ឃើញថាតម្រូវការចង់ទទួលចំណេះដឹងបច្ចេកទេសចិញ្ចឹមត្រីរបស់កសិករជាច្រើនដែលបច្ចុប្បន្នកំពុងតែជួបប្រទេះការខ្វះខាតម្ហូបអាហាត្រីប្រចាំគ្រួសារ ហើយដែលអ្នកជំនាញរដ្ឋបាលជលផល មិនអាចចុះបង្ហាត់កសិករទាំងអស់ក្នុងព្រះរាជជាណាចក្រកម្ពុជាអោយចេះចញ្ចឹមត្រីបាន រដ្ឋបាលជលផលរៀបចំចងក្រងសៀវភៅផ្សព្វផ្សាយស្តីពី (**បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ**) ហើយបានចែកចាយជូនដល់ប្រជាកសិករក្នុងបណ្តាលខេត្តជាច្រើន តាមរយៈអ្នកជំនាញជលផល ដែលកំពុងជួយផ្សព្វផ្សាយបច្ចេកទេសចញ្ចឹមត្រី។ ម្យ៉ាងទៀតដោយមានអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានជួយជំរុញការងារចិញ្ចឹមត្រីនេះដល់កសិករនៅតាមជនបទផងដែរនោះធ្វើឱ្យកសិករមួយភាគធំខ្វះកូនត្រីពូជសម្រាប់ចិញ្ចឹម។ ហេតុនេះរដ្ឋបាលជលផលបានផលិតសៀវភៅផ្សព្វផ្សាយស្តីពី (**បច្ចេកទេសបំប៉នកូនត្រីជាលក្ខណៈគ្រួសារ**) ហើយនិងមានគម្រោងរៀបចំផលិតសៀវភៅបច្ចេកទេសមួយទៀតស្តីពី(**បច្ចេកទេសបង្កាត់និងភ្ញាស់ត្រីជាលក្ខណៈគ្រួសារ**) សំដៅជួយបង្ហាត់បង្រៀនកសិករ ដែលមានបទពិសោធន៏ចីញ្ចឹមត្រីជាច្រើនឆ្នាំឱ្យចេះបច្ចេកទេសបំប៉ន និងផលិតកូនត្រីដើម្បីជួយដោះស្រាយបញ្ហាកង្វះខាត់កូនត្រីពូជសម្រាប់ចិញ្ចឹម ។

ដូចនេះដើម្បីឱ្យសៀវភៅ "បច្ចេកទេសបំប៉នកូនត្រី" បម្រើផលប្រយោជន៏ល្អដល់អ្នកចិញ្ចឹមត្រី ពិសេសកសិករដែលមានបទពិសោធន៏ចិញ្ចឹមត្រីហើយ រដ្ឋបាលជលផលសំណូមពរឱ្យគ្រួសារកសិករចិញ្ចឹមត្រីទាំអស់ បន្ថែមជាក្រុមពិភាក្សគ្នាអានសៀវភៅនេះដោយយកចិត្តទុកដាក់នោះសៀវភៅនេះនិងណែនាំ និងបង្ហាត់បង្រៀនអ្នកឱ្យចេះពីបច្ចេកទេសបំប៉នកូនត្រីបានប្រាកដ។

## មាតិកា


**បច្ចេកទេសបំប៉នកូនត្រី-------------------------១**

**១ - ការថែបំប៉នកូនត្រីក្នុងស្រះ---------------------------------១**

ក- ការថែបំប៉នកូនត្រីមេ្យា និងកូនត្រី------------------------------២

ក១- ស្រះ និងការរៀបចំស្រះបំប៉នកូនត្រីមេ្យា-------------------២

ក២- ស្រះ និងការរៀបចំស្រះបំប៉នកូនត្រីពូជ-------------------៤

ក៣- ការលែងកូនត្រីចូលស្រះបំប៉ន--------------------------៥

ក៤- ការប្រើប្រាស់ចំណីបន្ថែម ក្រោយពេលលែងកូនត្រី-----------៦

ក៥- ការប្រើប្រាស់ជី ក្រោយពេលលែងកូនត្រី------------------៧

ខ- ការគ្រប់គ្រង-------------------------------------------------៩

**២ - ការបំប៉នកូនត្រីក្នុងហាប៉ា-----------------------------------១២**

ក- បច្ចេកទេសដេហាប៉ា និងការរៀបចំហាប៉ាក្នុងស្រះ----------------១២

ខ- ការថែបំប៉នកូនត្រីមេ្យា និងកូនត្រីពូជ--------------------------១៤

ខ១- ការលែងកូនត្រីចូលហាប៉ាបំប៉ន-------------------------១៤

ខ២- ការប្រើប្រាស់ចំណីបន្ថែម ក្រោយពេលលែងកូនត្រី----------១៤

ខ៣- ការប្រើប្រាស់ជី ក្រោយពេលលែងកូនត្រី-----------------១៥

គ- ការគ្រប់គ្រង-------------------------------------------------១៥

**បច្ចេកទេសដឹកជញ្ជូនកូនត្រី-------------------១៧**

១- ការរៀបចំកូនត្រីមុនពេលដឹកជញ្ជូន----------------------------១៧

២- ការដឹកជញ្ជូនកូនត្រី---------------------------------------១៨

ក- ការដឹកជញ្ជូន ដោយប្រើថង់ផ្លាស់ស្ទិក--------------------១៨

ខ- ការដឹកជញ្ជូន ដោយប្រើធុង ឬធ្នាំង----------------------១៩

# បច្ចេកទេសបំប៉នកូនត្រី

## ១. ការថែបំប៉នកូនត្រីក្នុងស្រះ

ការថែបំប៉នកូនត្រីក្នុងស្រះ ត្រូវបំប៉នជាពីរដំណាក់កាលផ្សេងៗគ្នាគឺ : ដំណាក់កាលថែបំប៉នកូនត្រីម្សៅ និងដំណាក់កាលថែបំប៉នកូនត្រីម្សៅ និងដំណាក់កាលថែបំប៉នកូនត្រីពូជ។ សម្រាប់កសិករមានដើមទុនតិច គួរជ្រើសរើសប្រភេទត្រីទាំងឡាយណាដែលស៊ីចំណីធម្មជាតិមានស្រាប់នៅក្នុងស្រះជាអាហារសំខាន់ និងចំណីបន្ថែមអាចរកបាន ឬ មានស្រាប់នៅតាមមូលដ្ឋាន ភូមិ ឃុំ របស់ខ្លួន ដូចជា កន្ទក់ ចុងអង្ករ ជន្លេន កណ្ដៀរ ចកបាយទា កាកសំណល់បន្លែ ឬ ផ្ទះបាយជាដើម...។ល។ ប្រភេទត្រីទាំងនោះរួមមានដូចជា : ត្រីឆ្ពិន ត្រីទីឡាព្យ៉ា ត្រីកាបសាមញ្ញ ត្រីកាបស និងត្រីកាបឥណ្ឌា (ដូចរូបភាពខាងក្រោម) ។


ត្រីឆ្ពិន


ត្រីកន្ធរ


ត្រីទីឡាព្យ៉ា


ត្រីកាបសាមញ្ញ


ត្រីកាបស


ត្រីកាបឥណ្ឌា (ម្រីហ្គាល់)


ត្រីកាបឥណ្ឌា (រ៉ូហ៊ូ)

## ក. ការថែបំប៉នកូនត្រីម្សៅ និងកូនត្រីពូជ

កូនត្រីម្សៅ គឺជាកូនត្រីមានទំហំតូចៗ ដែលទើបនិងញាស់ និងចាប់ផ្តើមចេះស៊ីចំណី ។ ចំណែកកូនត្រីពូជ មានទំហំធំជាងកូនត្រីម្សៅ ។ ការថែបំប៉នកូនត្រីម្សៅក្នុងស្រះទាមទារត្រូវយកចិត្តទុកដាក់បំផុត ដើម្បីឱ្យកូនត្រីមានបរិមាណរស់ច្រើន និងធំធាត់ឆាប់រហ័ស ។ ក្រោយពីថែបំប៉នកូនត្រីម្សៅក្នុងរយៈពេលពី ២-៣ សប្តាហ៍នោះកូនត្រីមាន ទំហំកាន់តែធំ ធ្វើឱ្យទីធ្លារស់នៅកាន់តែចង្អៀត ដែលមានផលប៉ះពាល់មិនល្អដល់ការលូតលាស់របស់កូនត្រី ដូចច្នេះចាំបាច់យើងត្រូវចាប់រំលែកកូនត្រីមកដាក់បំប៉នក្នុងស្រះមួយផ្សេងទៀត ដើម្បីឱ្យកូនត្រីលូតលាស់បានឆាប់រហ័ស ។ បច្ចេកទេសថែបំប៉នកូនត្រីម្សៅ និងកូនត្រីពូជ មានដូចខាងក្រោមនេះ :

### ក១- ស្រះ និងការរៀបចំស្រះបំប៉នកូនត្រីម្សៅ

- ស្រះថែបំប៉នកូនត្រីម្សៅ គួរមានទំហំតូចល្មម ដើម្បីងាយស្រួលក្នុងការថែបំប៉ន ដូចជាទំហំពី ៥០ ទៅ ១៥០ ម៉ែត្រការេ ឬ មានបណ្តោយពី ១០ ម៉ែត្រ ទៅ ២០ ម៉ែត្រ ទទឹងមានពី ៥ ទៅ ១០ ម៉ែត្រ និងមានជម្រៅ 0.៥ ម៉ែត្រ (ដូចរូបភាពខាងក្រោម) ។
- ដើម្បីថែបំប៉នកូនត្រីម្សៅមានបរិមាណរស់ច្រើន ស្រះថែបំប៉នកូនត្រីម្សៅ ចាំបាច់ត្រូវរៀបចំឱ្យបានស្អាតល្អ គឺគ្មានត្រីកាច កង្កែប កូនក្អាត់ ពស់ អន្លង់ សត្វដង្កូវរែក ទោមក្តាមទូក... ។ល ។ ដែលស៊ីបំផ្លាញកូនត្រីម្សៅជាអាហារ ។



ស្រះថែបំប៉នកូនត្រីមានសំណាញ់ព័ទ្ធជុំវិញ



រូបភាពសត្វល្អិត បំផ្លាញកូនត្រី

- ដូចនេះ ស្រះត្រូវបូមទឹកពង្រីងឱ្យអស់ ដើម្បីចាប់ត្រីកាច កង្កែប កូនក្អាត់ ពស់ អន្ទង់...។ ល។ ទាំងអស់នេះ កុំឱ្យមានសល់ក្នុងស្រះ រួចស្តារភក់បាតស្រះទុកឱ្យមានជម្រៅតែពី១០ ទៅ ២០ សង់ទីម៉ែត្រ។

- រួចបាចកំបោរពី ៣ ទៅ ៥ គ.ក្រ ក្នុង ១០០ម$^{២}$ សម្រាប់ស្រះចាស់ ឬ ពី ១០ ទៅ ១៥ គ.ក្រ ក្នុង ១០០ម$^{២}$ សម្រាប់ស្រះថ្មី និងទុកស្រះហាលថ្ងៃ ចំនួន ២-៣ ថ្ងៃ។

- បន្ទាប់មកបង្ហូរទឹកចូលស្រះដោយប្រើតម្រងច្រោះ ដើម្បីការពារកុំឱ្យមានត្រីកាច ឬសត្វល្អិតចូលស្រះ និងត្រូវមានទ្រនាប់ទឹកបាញ់ចូលក្នុងស្រះ ដើម្បីកុំឱ្យទឹកស្រះល្អក់។



ស្រះបាចកំបោរហើយ



ស្រះបញ្ចូលទឹកដោយប្រើតម្រង និងទ្រនាប់

- ក្រោយពីស្រះបង្ហូរទឹកចូល និងសាបជាតិកំបោរអស់ហើយ ត្រូវលែងកូនត្រីម្សៅចូលក្នុងស្រះភ្លាម ដើម្បីកុំឱ្យមានសត្វល្អិតកើតក្នុងស្រះ មុនពេលដាក់កូនត្រីម្សៅបំប៉ន។

- ដូចនេះ ពេលរៀបចំស្រះថែបំប៉នកូនត្រីម្សៅ មិនត្រូវប្រើជីដាក់ក្នុងស្រះទេ ព្រោះវានិងកើតសត្វល្អិតច្រើន ស៊ីបំផ្លាញកូនត្រីម្សៅ។ ប៉ុន្តែក្រោយពេលបំប៉នកូនត្រីម្សៅមានទំហំធំ ស្រះចាំបាច់ត្រូវប្រើជី ដើម្បីបង្កើនបរិមាណចំណី ធម្មជាតិដែលជាចំណី សំខាន់សម្រាប់កូនត្រី (មានបញ្ជាក់ពីរបៀបប្រើជី ក្រោយពេលដាក់កូនត្រីចិញ្ចឹមបំប៉ននៅមេរៀនខាងក្រោយ)។

### ក២- ស្រះ និងការរៀបចំស្រះបំប៉នកូនត្រីពូជ

- ស្រះថៃបំប៉នកូនត្រីពូជ អាចមានទំហំប៉ុនទំហំស្រះថៃបំប៉នកូនត្រីម្សៅ ឬមានទំហំធំជាងនេះក៏បាន ប៉ុន្តែកុំឱ្យមានទំហំធំពេក ព្រោះពិបាកគ្រប់គ្រង។ ជាទូទៅសម្រាប់កសិករ ទំហំស្រះបំប៉នកូនត្រីពូជអាចមានពី ១៥០ ទៅ ២០០ ម៉ែត្រការេ ឬមានបណ្តោយពី ១៥ ម៉ែត្រ ទៅ ២០ ម៉ែត្រ និងទទឹង ១០ ម៉ែត្រ និងមានជម្រៅ 0.៥ ម៉ែត្រ ទៅ ១ ម៉ែត្រ ។

- ក្រោយពីកូនត្រីម្សៅមានទំហំធំ ត្រូវចាប់វាផ្ទេរទៅបំប៉នក្នុងស្រះមួយផ្សេងទៀត ដែលត្រូវរៀបចំតាមវិធីដូចបានជំរាប់ខាងលើ តែស្រះនេះត្រូវប្រើជី ដើម្បីបង្កើនសត្វល្អិតប្លង់តុង ដែលជាចំណីសំខាន់របស់កូនត្រីពូជ។

- ដូចនេះ ស្រះថៃបំប៉នកូនត្រីពូជ ត្រូវប្រើជីដាក់ក្នុងស្រះ។ ប្រភេទជីដែលដាក់ប្រើសម្រាប់កសិករ គឺ ជីធម្មជាតិ ដូចជា លាមកគោ ក្របី លាមកមាន់ ទា ជ្រូក ជាដើម ដោយដាក់វាត្រាំងក្នុងរណ្តៅជីរយៈពេល ១ សប្តាហ៏ ទើបបង្ហូរទឹកជីនោះចូលក្នុងស្រះ (ដូចរូបភាពខាងក្រោម)។

- ក្រោយពេលដាក់ជីហើយ រយៈពេលប្រមាណពី ២ ទៅ ៣ថ្ងៃ បើសង្កេតឃើញទឹកស្រះមានពណ៌បៃតង ទើបលែងកូនត្រីពូជចូលក្នុងស្រះបាន ។

- ម្យ៉ាងទៀត ដើម្បីថៃបំប៉នកូនត្រីម្សៅ និងកូនត្រីពូជមានបរិមាណរស់ច្រើន គួរព័ទ្ធសំណាញ់ជុំវិញស្រះ ដើម្បីការពារកុំឱ្យត្រីកាច ឬកង្កែប កូនក្អាត់ ពស់ ឬ កណ្តុរចូលក្នុងស្រះស៊ីកូនត្រី (ដូចរូបភាពខាងក្រោម) ។




ការរៀបចំស្រះដោយប្រើរណ្តៅជី

ស្រះបំប៉នកូនត្រីរៀបចំហើយ
និងមានសំណាញ់ព័ទ្ធជុំវិញ



## ក៣ - ការលែងកូនត្រីចូលស្រះបំប៉ន

- លក្ខខណ្ឌចាំបាច់ មុននិងលែងកូនត្រីចូលក្នុងស្រះបំប៉ន ត្រូវប្រាកដថា គ្មានត្រីកាច ឬ កង្កែប កូនក្អាត់ ពស់ ...។ ល ។ និងគ្មានសត្វល្អិតប្លង់តុង នៅក្នុងស្រះបំប៉នកូនត្រីម្សៅ ។
- ចំពោះកូនត្រីម្សៅ អាចដាក់បំប៉នក្នុងស្រះ បានចំនួនពី ២០០ ទៅ ៣០០ ក្បាល ក្នុង ១ម៉ែត្រ ការេ ។
- និងកូនត្រីពូជ ទំហំពី ២ ទៅ ៣ សង់ទីម៉ែត្រ អាចដាក់បំប៉នក្នុងស្រះ បានចំនួន ពី ២០ ទៅ ៣០ ក្បាល ក្នុង ១ម៉ែត្រ ការេ ។
- កូនត្រីដែលដាក់បំប៉ន ត្រូវមានទំហំប៉ុនគ្នា បើមិនដូចនេះទេ កូនត្រីតូចមិនហ៊ានប្រជែងស៊ីចំណី ជាមួយត្រីធំ ឬ កូនត្រីធំអាចស៊ីកូនត្រីតូច ករណីពេលខ្វះចំណី ។
- ដើម្បីឱ្យកូនត្រីលូតលាស់បានល្អ និងងាយស្រួលក្នុងការរាប់កូនត្រីលក់ កសិករគួតែបំប៉នកូនត្រី ដាច់ដោយឡែកពីគ្នា តាមប្រភេទត្រីនីមួយៗ ។
- ត្រូវលែងកូនត្រីនៅពេលព្រឹកមានពន្លឺថ្ងៃ ចៀសវាងលែងកូនត្រីពេលល្ងាច មេឃជិតភ្លៀង និងក្រោយពេលភ្លៀងរួច ។
- មុននិងលែងកូនត្រីចូលក្នុងស្រះ ត្រូវត្រាំថង់ ឬធុងដាក់កូនត្រី នៅក្នុងស្រះដែលត្រូវលែងរយៈពេលពី ៥ ទៅ ១០ នាទីជាមុនសិន រួចស្រាយមាត់ថង់បាចទឹកស្រះបញ្ចូលថង់ ឬ ធុងដាក់កូនត្រីបន្តិចម្តងៗ ដើម្បីធ្វើឱ្យសិតុណ្ហភាពទឹកក្នុងថង់ និងធុងដាក់កូនត្រី ដូចគ្នា និងសីតុណ្ហភាពទឹកក្នុងស្រះ (ដូចរូបភាពខាងក្រោម) ។
- បន្ទាប់មក ត្រូវផ្អៀងមាត់ថង់ ឬធុងដាក់កូនត្រី ឱ្យកូនត្រីហែលចេញតាមសម្រួល (ដូចរូបភាពខាងក្រោម) ។



ទំហំកូនត្រីពូជអាចដាក់ចិញ្ចឹមបានក្នុងស្រះ



របៀបលែងកូនត្រីចូលក្នុងស្រះ

## ក៩ –   ការប្រើប្រាស់ចំណីបន្ថែម   ក្រោយពេលលែងកូនត្រី

ក្រោយពេលលែងកូនត្រី ចាំបាច់ត្រូវផ្តល់ចំណីបន្ថែម ដើម្បីឱ្យកូនត្រីលូតលាស់ឆាប់រហ័ស ។ គួររៀបចំ ចំណីបន្ថែមសម្រាប់កូនត្រី ដូចខាងក្រោម៖

- ចំពោះកូនត្រីម្សៅ ត្រូវស្ងោរពងទា បកយកពងលឿងមកកិនឱ្យម៉ត់ជាម្សៅ ដាក់ឱ្យកូនត្រីស៊ីពី ៣-៤ ដង ក្នុង ១ថ្ងៃ។ ក្រោយរយៈពេល ១ សប្តាហ៍ យកត្រីល្អិតៗ ឬកាកសំណល់ត្រីហាលស្ងួត ឬចំណីគ្រាប់ ចំនួន ៥០%បុកឱ្យម៉ត់លាយជាមួយកន្ទក់ ៥០%ដាក់ឱ្យកូនត្រីម្សៅស៊ីចំនួន ៣-៤ ដង ក្នុង ១ថ្ងៃ ។
- ក្រោយពេលបំប៉នកូនត្រីម្សៅបានរយៈពេល ១ ខែ កូនត្រីមានទំហំធំ ទំហំពី ២-៣ ស.ម គួរចាប់រំលែកដាក់បំប៉នក្នុងកូនត្រីពូជ ដើម្បីឱ្យកូនត្រីឆាប់លូតលាស់បានល្អ។ ចំនួនត្រីដាក់បំប៉ន គួរមានចំនួនពី២០ ទៅ៣០ ក្បាល ក្នុង ១ម៉ែត្រការេ ។ មកដល់ដំណាក់កាលនេះ ត្រូវប្រើជីដាក់ស្រះបំប៉នកូនត្រី ដើម្បីឱ្យស្រះមានពណ៌បៃតងល្អ សម្បូរចំណីធម្មជាតិ សម្រាប់ជាចំណីកូនត្រី ( មើលមេរៀនប្រើជី ក្រោយពេលលែងកូនត្រី) ។
- ក្រៅពីនេះត្រូវប្រើចំណីបន្ថែមឱ្យកូនត្រីស៊ីដើម្បីឱ្យកូនត្រីលូតលាស់ឆាប់រហ័ស ដូចជាកិនត្រីហាល ឬចំណីគ្រាប់២០% លាយជាមួយកន្ទក់ ៦០% ចុងអង្ករ១០% និងសណ្តែកសៀង ១០% ដាក់ស្ងោរលាយឱ្យកូនត្រីស៊ី ៣ ដង ក្នុងមួយថ្ងៃ និងត្រូវប្រើស៊ុមដាក់ចំណី ដើម្បីងាយស្រួលពិនិត្យបរិមាណចំណីដាក់អោយត្រីស៊ី ។



ត្រីហាល

ឬ



ចំណីគ្រាប់ ២០%

ផ្សំជាមួយ



កន្ទក់ ៦០%

ផ្សំជាមួយ



ចុងអង្ករ ១០%

ផ្សំជាមួយ



សណ្តែកសៀង ១០%

យកទៅកូរចំអិនជាមួយគ្នា →



→ ទទួលបានចំណីផ្សំសម្រេច →



- បរិមាណចំណីត្រូវដាក់ឱ្យត្រីស៊ី ទៅតាមសភាពកូនត្រីស៊ីចំណីជាក់ស្តែង ចៀសវាងការដាក់ចំណីច្រើនពេកដែលនាំឱ្យសល់ ស្អុយទឹក និងចៀសវាងការដាក់ចំណីតិចពេកដែលនាំឱ្យកូនត្រីស៊ីចំណីមិនបានគ្រប់គ្រាន់។

- គួរដាក់ឱ្យចំណីកូនត្រីនៅពេលព្រឹកពន្លឺថ្ងៃ- នៅពេលថ្ងៃ- និងនៅពេលរសៀលមានបន្លឺថ្ងៃ ចៀសវាងចំណីត្រី នៅពេលមេឃជិតភ្លៀង - កំពុងភ្លៀង - និងក្រោយពេលភ្លៀងរួច។

- ត្រូវផ្តល់ចំណីបន្ថែមនេះ សម្រាប់បំប៉នកូនត្រី រហូតដល់កូនត្រីមានទំហំធំ ដែលអាចចាប់លក់ឱ្យកសិករទិញយកទៅចិញ្ចឹមបាន។

### ក៥- ការប្រើប្រាស់ជី ក្រោយពេលលែងកូនត្រី

ក្រោយពីការផ្តល់ចំណីបន្ថែមខាងលើ ចាំបាច់ត្រូវប្រើជីដាក់ស្រះ ដើម្បីបង្កើនចំណីធម្មជាតិ (រុក្ខជាតិប្លង់តុង និងសត្វប្លង់តុង) ដែលជាចំណីសំខាន់សម្រាប់ការបំប៉នកូនត្រីពូជ ដូចនេះគួរអនុវត្តការប្រើជីដាក់ស្រះ តាមរបៀបដូចខាងក្រោម៖

- សម្រាប់កសិករ គួតែប្រើប្រាស់ជីធម្មជាតិដែលមានស្រាប់ក្នុងមូលដ្ឋាន ដូចជា ជីលាមកគោ ក្របី ជ្រូក មាន់ ទា និង ដើមទន្ទ្រានខែត្រ ជាដើម តាមរបៀបខាងក្រោម ដោយមិនចាំបាច់ប្រើជីគីមីក៏ធ្វើឱ្យទឹកស្រះសម្បូរចំណីធម្មជាតិបានដែរ។ ចំពោះស្រះបំប៉នកូនត្រីម្សៅ ក្រោយពីលែងកូនត្រីម្សៅរួច ឬនៅពេលកូនត្រីម្សៅមានទំហំតូចមិនត្រូវប្រើជីដាក់ស្រះទេ ពីព្រោះកូនត្រីនិងបាត់បង់ដោយសារសត្វល្អិតប្លង់តុងកើតក្នុងស្រះ និងរុំស៊ីកូនត្រី។






- ប៉ុន្តែ ចាំបាច់ត្រូវប្រើជីធម្មជាតិនេះ ឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ដើម្បីចៀសវាងធ្វើឱ្យទឹកស្រះស្អុយ ត្រីពុល និងកូនត្រីងាប់ ។ ដូចនេះ ត្រូវដាក់ជីលាមកគោ ក្របី ជ្រូក មាន់ ទា និង ដើមទន្ទ្រានខែត្រ ត្រាំក្នុងរណ្ដៅជីរយៈពេល ១ សប្ដាហ៍ ទើបបង្ហូរទឹកជីនេះចូលក្នុងស្រះ នៅពេលថ្ងៃមានពន្លឺព្រះអាទិត្យ ចៀស វាងបង្ហូរទឹកជីនេះចូលក្នុងស្រះ នៅពេលគ្មានពន្លឺថ្ងៃ ឬ ពេលមេឃជិតភ្លៀង- និងក្រោយពេលមេឃភ្លៀងរួច ។

- ត្រូវបង្ហូរទឹកជីនេះចូលក្នុងស្រះបន្តិចម្ដងៗ ចៀសវាងបង្ហូរចូលស្រះច្រើនតែម្ដងក្នុងពេលតែមួយ ដើម្បីកុំឱ្យទឹកស្រះស្អុយ ត្រីពុល និងកូនត្រីងាប់ ។

- នៅពេលទឹកស្រះសម្បូរចំណីធម្មជាតិហើយ ត្រូវបញ្ឈប់ការបង្ហូរទឹកជីចូលស្រះ រហូតដល់ស្រះខ្វះចំណីធម្មជាតិវិញ ។

- យើងអាចដឹងថា ទឹកស្រះបម្សូរចំណីធម្មជាតិបាន ដោយសង្កេតមើលទឹកស្រះមានពណ៌បៃតង ឬក៏ប្រើក្រមា និងកែវដួសត្រងទឹកក្នុងស្រះមកពិនិត្យមើលបរិមាណសត្វល្អិតប្លុងតុងដូចរូបខាងក្រោម ។ បើសង្កេតឃើញ សត្វល្អិតប្លុងតុងច្រើនក្នុងកែវ នោះបញ្ជាក់ថា ទឹកស្រះនោះសម្បូរចំណីធម្មជាតិគ្រប់គ្រាន់សម្រាប់បំប៉នកូនត្រីពូជហើយ ។

- ក្នុងករណីមិនឃើញមានសត្វល្អិតប្លុងតុងច្រើនក្នុងកែវទេ គួរបង្ហូរទឹកជីពីក្នុងរណ្ដៅជីចូលស្រះបន្ថិចថែមទៀត ប៉ុន្តែកុំបង្ហូរចូលច្រើនពេក នាំឱ្យទឹកស្រះស្អុយត្រីពុល និងកូនងាប់ ។



របៀបដួសសត្វល្អិតប្លុងតុងពីស្រះ



រូបភាពសត្វល្អិតប្លុងតុង



រូបភាពសត្វល្អិតប្លុងតុង

## ខ. ការគ្រប់គ្រង

- ជាទូទៅ កូនត្រីម្យៅត្រូវបំប៉នរយៈពេលពី ៣-៤ អាទិត្យ ឬ បំប៉នរហូតដល់ទំហំពី ២ ទៅ ៣ សង់ទីម៉ែត្រ រួចចាប់វាលែកដាក់បំប៉នក្នុងស្រះបំប៉នកូនត្រីពូជ ។

- ចំពោះកូនត្រីពូជទំហំ ២ ទៅ ៣ សង់ទីម៉ែត្រ ត្រូវបំប៉នរយៈពេលពី ៣ ទៅ ៤ អាទិត្យបន្តទៀត រហូតដល់កូនត្រីមានទំហំពី ៥ ទៅ ៦ សង់ទីម៉ែត្រ ទើបអាចលក់ឱ្យកសិករយកចញ្ចឹមបាន។

- ដើម្បីបំប៉នកូនត្រីក្នុងស្រះទទួលបានលទ្ធផលល្អ ត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោមនេះ :

- នៅពេលរៀបចំស្រះបំប៉នកូនត្រីម្យៅ និងក្នុងរយៈពេលបំប៉នកូនត្រីម្យៅក្នុងស្រះ ឬនៅពេលកូនត្រីម្យៅនៅមានទំហំតូច មិនត្រូវប្រើជីដាក់ក្នុងស្រះទេព្រោះវាធ្វើឱ្យកូនត្រីងាប់ដោយសារទឹកស្រះស្អុយ និងកូនត្រីបាត់បង់ ដោយសារសត្វល្អិតប្លុងតុងកើតក្នុងស្រះ និងរុំព័ទ្ធស៊ីកូនត្រី។
- ប៉ុន្តែត្រូវប្រើជីដាក់ស្រះ នៅពេលកូនត្រីមានទំហំធំ ដោយត្រូវអនុវត្តរបៀបប្រើជីឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ដូចបានបញ្ជាក់ខាងលើ ។
- ត្រូវធ្វើឱ្យទឹកស្រះមានពណ៌បៃតង ឬមានចំណីធម្មជាតិសម្បូរក្នុងស្រះជានិច្ច នៅពេលកូនត្រីមានទំហំធំ ដើម្បីឱ្យកូនត្រីមានបរិមាណរស់ច្រើន និងធំធាត់ឆាប់រហ័ស។





រូបភាពសត្វល្អិតប្លុងតុងក្នុងកែវ

ប្រភេទខ្លះនៃសត្វល្អិតប្លុងតុង មើលក្នុងមីក្រូទស្សន៍

- ត្រូវផ្តល់ចំណីបន្ថែមឱ្យបានទៀងទាត់ពេលវេលា ដើម្បីឱ្យកូនត្រីធំធាត់ឆាប់រហ័ស
- ត្រូវការពារកុំឱ្យមានត្រីស្រែ ពស់ កង្កែប កូនក្អាត់ កណ្តុរ.......ចូលក្នុងស្រះស៊ីកូនត្រី បើមានលទ្ធភាពត្រូវព័ទ្ធសំណាញ់ជុំវិញស្រះ ដើម្បីឱ្យកូនត្រីមានបរិមាណរស់ច្រើន។
- ក្រោយពេលបំប៉នកូនត្រីម្សៅមានទំហំពី ២ ទៅ ៣ សង់ទីម៉ែត្រ ត្រូវចាប់វារំលែកទៅ បំប៉នក្នុងស្រះកូនត្រីពូជ ដើម្បីឱ្យកូនត្រីលូតលាស់ឆាបរហ័ស។
- មិនត្រូវមានដើមឈើធំៗនៅជុំវិញស្រះ បាំងពន្លឺព្រះអាទិត្យ និងស្លឹកជ្រុះចូលក្នុងស្រះ ដែលជាហេតុធ្វើឱ្យទឹកស្រះស្អុយ ខ្វះខ្យល់អុកស៊ីសែន កូនត្រីពុលនិងងាប់។
- ហាមមិនឱ្យបោកគក់ខោ អាវ ឬគោ ក្របីចុះមុជទឹកនិងត្រាំក្នុងស្រះ ឬដាក់ស្លឹក ឬឈើ ត្រាំក្នុងស្រះ និងលាងធុងថ្នាំក្នុងស្រះ ដែលជាហេតុធ្វើឱ្យកូនត្រីពុល និងងាប់ឆាប់រហ័ស។



ហាមបោកគក់ខោ អាវក្នុងស្រះ



ហាមត្រាំស្លឹកក្នុងស្រះ



ហាមលាងធុងបាញ់ថ្នាំពុលក្នុងស្រះ

- ក្នុងករណី កូនត្រីងើបក្បាលច្រើននៅផ្ទៃទឹក ភាគច្រើននៅពេលព្រឹកព្រលឹមមុនថ្ងៃរះ គឺ បណ្ដាលមកពីទឹកស្រះមិនល្អ ខ្វះខ្យល់អុកស៊ីសែនរលាយក្នុងទឹកស្រះដូចនេះចាំបាច់ត្រូវអនុវត្ត ដូចខាងក្រោម ៖

- បាចសាចទឹកស្រះឡើងលើ ដើម្បីធ្វើឱ្យខ្យល់អុកស៊ីសែនដែលមានក្នុងបរិយាកាស រលាយចូលទៅក្នុងទឹកស្រះបាន
- ផ្អាកការបង្ហូទឹកជីចូលក្នុងស្រះ
- ក្នុងករណី កូនត្រីនៅតែបន្តងើបលើផ្ទៃទឹកច្រើន ទោះជានៅពេលមានពន្លឺថ្ងៃគ្រប់គ្រាន់ក៏ដោយ ពេលនោះបើមានលទ្ធភាពត្រូវបង្ហូរទឹកចាស់ចេញពីក្នុងស្រះមួយចំនួន និងបន្ថែមទឹកថ្មីល្អស្អាត គ្មានជាតិពុលចូលក្នុងស្រះជំនួនទឹកចាស់វិញ ដោយប្រើតម្រងច្រោះ និងទ្រនាប់ទ្រកម្លាំងទឹកបាញ់ចូលស្រះ ដើម្បីកុំឱ្យទឹកស្រះល្អក់ ដែលនាំឱ្យកូនត្រីពុល និងងាប់។
- ក្នុងករណីថ្ងៃបន្ទាប់ កូនត្រីនៅតែពុល ទោះបីមានពន្លឺថ្ងៃគ្រប់គ្រាន់ក៏ដោយ យើងគួរចាប់រំលែកកូនត្រីចេញខ្លះ និងយកទៅបំប៉នក្នុងស្រះផ្សេង១ទៀត។ ការចាប់កូនត្រីរំលែកនេះត្រូវធ្វើនៅពេលកូនត្រីឈប់ពុល។





**សកម្មភាពបាចទឹកស្រះ នៅពេលត្រីពុលងើបក្បាលនៅពេលព្រឹក**

## ២. ការបំប៉នកូនត្រីក្នុងហាប៉ា

### ក. បច្ចេកទេសដេរហាប៉ា និងការរៀបចំហាប៉ាក្នុងស្រះ

ហាប៉ាជាសំណាញ់ជ័រខៀវ ឬផ្ទាំងស្បៃនីឡុងក្រឡាល្អិត ដែលគេដេរមានរាងដូច មុងដេក សម្រាប់ប្រើសកម្មភាពបំប៉នកូនត្រី និងផលិតកូនត្រី (ដូចរូបភាពខាងក្រោម)។ ដើម្បីដេរហាប៉ាសម្រាប់បំប៉នកូនត្រី យើងត្រូវអនុវត្តតាមវិធីខាងក្រោម ៖

- យកសាច់អញ្ចងខៀវ ឬសំណាញ់ជ័រខៀវ ឬផ្ទាំងស្បៃនីឡុងមកដេរឱ្យមានរាងដូចមុងដេក។
- ចំពោះហាប៉ាបំប៉នកូនត្រីម្សៅ ត្រូវយកផ្ទាំងស្បៃនីឡុងក្រលាល្អិតមកដេរ។
- ចំពោះហាប៉ាបំប៉នកូនត្រីពូជ ត្រូវយកសំណាញ់ជ័រខៀវមកដេរ។
- ហាប៉ាផ្គុំឡើងដោយសំណាញ់ ៣ ផ្ទាំង គឺផ្ទាំងជញ្ជាំងជុំវិញ ១ផ្ទាំង និងបាត ២ផ្ទាំង។
- ឧទាហរណ៍៖ យើងចង់ដេរហាប៉ាដែលមានបណ្តោយ ៣ម៉ែត្រ ទទឹង ២ម៉ែត្រ និងកម្ពស់ ១ម៉ែត្រ យើងត្រូវកាត់ផ្ទាំងសំណាញ់ដូចខាងក្រោម ៖
- ហាប៉ាត្រូវដេរឱ្យមានត្រចៀកបួន នៅកាច់ជ្រុកផ្នែកបាតផ្នែកខាងលើ និងត្រូវមានត្រចៀកសម្រាប់ស៊កខ្សែចង ចន្លោះពី ១ ទៅ ១ ប្រវែងកន្លះម៉ែត្រនៅផ្នែកខាងលើ ដើម្បីងាយស្រួលចងភ្ជាប់ទៅនិងបង្គោល ។
- ទំហំហាប៉ា ដែលនិយមប្រើ គឺមានបណ្តោយ ៣ម៉ែត្រ ទទឹង ២ម៉ែត្រ និងកម្ពស់ ១ម៉ែត្រ ។



រូបភាពហាប៉ាដេររួចហើយ




ផ្ទាំងសំណាញ់ជ័រក្រឡាល្អិតសម្រាប់ដេរហាប៉ា

**- ដើម្បីដំឡើងចងហាប៉ាក្នុងស្រះ យើងត្រូវ៖**

- មានបង្គោលឈើ ឬ ឫស្សី ចំនួន ៤ដើម សម្រាប់ចងហាប៉ា។
- រៀបចំស៊កខ្សែចងក្នុងត្រចៀកហាប៉ាឱ្យហើយស្រេច មុននឹងចុះចងទឹក។
- ដាក់ហាប៉ាកាច់ជ្រុងស្រះ ឬ កន្លែងដែលមានទឹករាក់ល្មមជម្រៅប្រហែល ១ម៉ែត្រ ដើម្បីងាយស្រួលត្រួតពិនិត្រ។
- ហាប៉ាត្រូវដាក់ក្នុងស្រះ ដែលមានទឹកពណ៌បៃតង និងដាក់កន្លែងណាមានពន្លឺថ្ងៃគ្រប់គ្រាន់ ហើយបាតហាប៉ាត្រូវចងពន្លិចចូលទៅក្នុងទឹកជម្រៅពី 0.៥ម ទៅ 0.៧ម ហើយមាត់លើនៃហាប៉ា ត្រូវចងឱ្យខ្ពស់ផុតពីទឹកពី 0.៣ម ទៅ 0.៥ម ដើម្បីកុំឱ្យកូនត្រីលោតចេញ ។
- បាតហាប៉ា ត្រូវដាក់ឱ្យផុតពីបាតស្រះ ដើម្បីចៀសវាងក្តាមកាត់បាតហាប៉ា។
- បើសិន បាតហាប៉ាអណ្តែត ឬប៉ោងឡើង យើងត្រូវយកដុំអិដ្ឋ ឬដុំថ្មមួយដុំតូច ដាក់នៅចំកណ្តាលបាតហាប៉ា ។







ការរៀបចំដំឡើង ហាប៉ានៅក្នុងស្រះ

## ខ. ការថែបំប៉នកូនត្រីមេ្យា និងកូនត្រីពូជ

### ខ១- ការលែងកូនត្រីចូលហាប៉ាបំប៉ន

- ការលែងកូនត្រីចូលហាប៉ាបំប៉ន ដូចគ្នានិងការលែងកូនត្រីចូលក្នុងស្រះបំប៉នខាងលើផងដែរ ។
- ចំពោះកូនត្រីទីឡាព្យ៉ា នៅពេលឃើញមានកូនត្រីហែលជាហ្វូងនៅក្នុងស្រះ កសិករអាចដួស ឬ ដង យកមកបំប៉នក្នុងហាប៉ាកូនត្រីមេ្យា (ដូចរូបភាពខាងក្រោម)
- ហាប៉ាមួយ ដែលមានទំហំបណ្តោយ ៣ម៉ែត្រ ទទឹង ២ម៉ែត្រ និងកម្ពស់ ១ម៉ែត្រ អាចដាក់បំប៉នកូនត្រីមេ្យា ៣000 ទៅ ៤000កូន ចំពោះកូនត្រីមានទំដហំ១ស.ម ឬ ៥00 ក្បាល ក្នុង ១ម៉ែត្រការេ ។
- ចំណែកកូនត្រីពូជ ទំហំពី ១.៥ ទៅ ២ សង់ទីម៉ែត្រ អាចដាក់បំប៉ក្នុងហាប៉ាខាងលើបានចំនួន ១៥00 ទៅ ២000កូន ឬ ២៥0 ក្បាល ក្នុង ១ម៉ែត្រការេ ។
- ចំពោះកូនត្រីកាបសាមញ្ញ និងកាបស មិនត្រូវដាក់បំប៉នក្នុងហាប៉ាជាមួយកូនត្រីឡាព្យ៉ា និងកូនត្រីឆ្ពិនទេ ព្រោះធ្វើឱ្យកូនត្រីកាបសាមញ្ញ និងកាបស លូតលាស់ យឺតដោយសារកូនត្រីឡាព្យ៉ា និងកុនត្រីឆ្ពិន ដណ្តើមស៊ីចំណីលឿន ។
- ដើម្បីឱ្យកូនត្រីលូតលាស់បានល្អ និងងាយស្រួលក្នុងការរាប់កូនត្រីលក់ កសិករគួរតែបំប៉នកូនត្រីក្នុងហាប៉ាដាច់ដោយឡែកពីគ្នា តាមប្រភេទត្រីនិមួយៗ ។



ការដួសកូនត្រីទីឡាព្យ៉ាពីក្នុងស្រះ



ការដាក់កូនត្រីប៉ននក្នុងហាប៉ា

### ៦២- ការប្រើប្រាស់ចំណីបន្ថែម ក្រោយពេលលែងកូនត្រី

គឺដូចគ្នានិងការថែបំប៉នកូនត្រីក្នុងស្រះដែរ ។

### ៦៣- ការប្រើប្រាស់ជី ក្រោយពេលលែងកូនត្រី

- ក្រៅពីចំណីបន្ថែមខាងលើ ចំណីធម្មជាតិ (រុក្ខជាតិប្លង់តុង និងសត្វប្លង់តុង) មានសារៈសំខាន់ណាស់ សម្រាប់ការថែបំប៉នកូនត្រី ។ ដូចនេះយើងត្រូវដួសប្លង់តុងពីក្នុងស្រះមកដាក់ឱ្យកូនត្រីស៊ីក្នុងហាប៉ា (ដូចរូបភាពខាងក្រោម) ។

- ទឹកស្រះដែលដាក់ហាប៉ា ត្រូវរៀបចំឱ្យមានពណ៌បៃតងជានិច្ច ដោយប្រើជីធម្មជាតិ ដូចបានរៀបចំ ក្នុងមេរៀនការបំប៉នកូនត្រីក្នុងស្រះ ។



គុណភាពទឹកស្រះមានពណ៌បៃតងល្អ

ការដួសសត្វល្អិតប្លង់តុងពីស្រះដាក់ក្នុងហាប៉ាបំប៉ន



## គ. ការគ្រប់គ្រង

ដើម្បីថែបំប៉នកូនត្រីក្នុងហាប៉ា ទទួលបានលទ្ធផលល្អ ត្រូវយកចិត្តទុកដាក់ដូចខាងក្រោយនេះ :

- ចំពោះហាប៉ានីមួយៗ មុននិងដំឡើងក្នុងទឹក ត្រូវត្រួតពិនិត្យមើលកន្លែងធ្លុះធ្លាយ និងដេរឱ្យបានជាប់មាំល្អ ។
- ត្រូវការពារកុំឱ្យមានពពួកសត្វល្អិតចង្រៃកាត់ហាប៉ា ដូចជា ក្ដាម កណ្ដុរ... ជាដើម ។
- ត្រូវដុសសំអាតហាប៉ា ២ដងក្នុងមួយអាទិត្យ ដោយប្រើដៃដុសថ្នមៗ មិនត្រូវប្រើច្រាសរឹងដុសហាប៉ាឡើយ ព្រោះនាំឱ្យរហែក ។ ការដុសសំអាតនេះគឺធ្វើឱ្យប្លង់តុងអាចចូលទៅក្នុងហាប៉ាបានច្រើន ។

- ត្រូវឧស្សាហ៍ត្រួតពិនិត្យមើលហាប៉ា ក្រែងមានកន្លែងធ្លុះធ្លាយ ។
- ត្រូវការពារ កុំអោយត្រីកាច ពស់ កង្កែប កាចាត ឬ កណ្ដុរ ចូលក្នុងហាប៉ាស៊ីកូនត្រី ។
- ត្រូវប្ដូទីតាំងចងហាប៉ា ទៅរកកន្លែងថ្មីជ្រៅល្មម ក្នុងករណីកន្លែងចាស់រាក់ពេក ។
- ករណីមានភ្លៀងត្រូវប្រុងប្រយ័ត្ន ក្រែងទឹកលិចហាប៉ា នាំឱ្យកូនត្រីចេញរួច ។
- ករណីស្រះមានស្លែ ហើយមានអណ្ដែតត្រាក្នុងហាប៉ា ត្រូវកៀរដួសវាចេញ ព្រោះនាំឱ្យកូនត្រីពុល ។
- ត្រូវផ្ដល់ចំណីបន្ថែមឱ្យកូនត្រីស៊ី ឱ្យបានទៀងទាត់ពេលវេលា ។
- ត្រូវដាក់ជីបន្ថែមក្នុងស្រះ ករណីទឹកស្រះលែងមានបណិបៃតង និងត្រូវឧស្សាហ៍ដួសត្វប្លង់តុងពីស្រះដាក់បន្ថែមក្នុងហាប៉ា ដើម្បីឱ្យកូនត្រីស៊ី ។



កង្កែប ត្រី លោតចូល ហាប៉ាស៊ីកូនត្រី



ហាប៉ាលិចក្នុងស្រះ ពេលមានភ្លៀងធ្លាក់

# បច្ចេកទេសដឹកជញ្ជូនកូនត្រី

## ១. ការរៀបចំកូនត្រី មុនដឹកជញ្ជូន

ពេលកូនត្រីពូជមានទំហំពី ៤ ទៅ ៦ស.ម ឬ ពី ២ ទៅ៣ ថ្នាំងដៃ យើងអាចចាប់លក់ឱ្យកសិករចញ្ចឹមបាន ។




កូនត្រីពូជ មុននឹងដឹកជញ្ជូនសម្រាប់លក់ឱ្យកសិករ :

- ត្រូវចាប់កូនត្រីពូជ ដែលត្រូវលក់ចេញពីស្រះ នៅពេលព្រឹកថ្ងៃរះ ដាក់ក្នុងហាប៉ា និងមិនត្រូវផ្តល់ចំណីឱ្យវាស៊ី ១ ថ្ងៃ មុននិងដឹកជញ្ជូន ។
- ចំពោះកូនត្រីពូជដែលត្រៀមលក់នៅក្នុងហាប៉ា រយៈពេលយូរថ្ងៃ យើងអាចឱ្យចំណីវាស៊ីបាន ហើយមិនត្រូវផ្តល់ចំណីឱ្យកូនត្រីស៊ីនៅមុនពេល១ថ្ងៃ ដឹកជញ្ជូនសំរាប់លក់ ។ ព្រោះបើកូនត្រីស៊ីចំណីឆ្អែត វានឹងបញ្ចេញលាមកយ៉ាងច្រើននៅក្នុងថង់ទឹកកូនត្រី ដែលបណ្តាលឱ្យមានកូនត្រីពុលងាប់ ។
- មិនត្រូវលក់កូនត្រី ទៅឱ្យកសិករណា ដែលមិនបានរៀបចំស្រះជាមុន ។
- អ្នកលក់ត្រូវពន្យល់អ្នកមកទិញកូនត្រី ឱ្យយល់ច្បាស់ពីរបៀបចញ្ចឹមត្រីជាមុនសិន ឬផ្តល់សៀវភៅបច្ចេកទេសចិញ្ចឹមត្រីទៅអ្នកទិញ (បើមាន) ទើបលក់កូនត្រីឱ្យគាត់ ។
- អ្នកលក់ត្រូវប្រើកញ្ច្រែង ដើម្បីរែងជ្រើសរើសកូនត្រីពូជឱ្យបានទំហំប៉ុនៗគ្នាសម្រាប់លក់ ។

## ២. ការដឹកជញ្ជូនកូនត្រី

ការដឹកជញ្ជូនកូនត្រី មានពីររបៀបគឺ គឺការដឹកជញ្ជូនដោយប្រើថង់ប្លាស់ស្ទិក និងការដឹកជញ្ជូនដោយប្រើធុង ឬឆ្នាំង។

### ក. ការដឹកជញ្ជូន ដោយប្រើថង់ប្លាស់ស្ទិក

- ការដឹកជញ្ជូនរបៀបនេះ សម្រាប់អនុវត្តផ្លូវឆ្ងាយ ដោយប្រើខ្យល់ធម្មជាតិ ឬខ្យល់អុកស៊ីសែន (បើមាន)។ អ្នកលក់គួរប្រើថង់ប្លាស់ស្ទិកពីរជាន់ទើបប្រសើរ ចៀសវាងថង់ធ្លាយពេលដឹកជញ្ជូន ។
- ថង់ប្លាស់ស្ទិក ដែលនិយមប្រើ មានទំហំបណ្តោយ ៨0.ស.ម និង ទទឹងមាត់ថង់ ៦0ស.ម។
- ត្រូវដាក់ទឹកស្រះ ១ភាគ ៤ នៃថង់ រួចដាក់កូនត្រីពូជពី ២00 ទៅ ៣00ក្បាល ក្នុង១ថង់។ ចំពោះកូនត្រីម្សៅ អាចដាក់ពី ១000 ទៅ ២000ក្បាល ក្នុងមួយថង់សំរាប់លក់ឱ្យកសិករណាដែលយកទៅបំប៉នទៀតតែប៉ុណ្ណោះ ។
-បន្ទាប់ពីដាក់កូនត្រីរួចហើយ ត្រូវទាញមាត់ថង់ចំហឱ្យខ្យល់ធម្មជាតិចូលរួចក្របួចមាត់ថង់ឱ្យរហ័សយកកៅស៊ូកងមកចងមាត់ថង់ឱ្យបានជិតល្អ។យើងអាចប្រើខ្យល់ធម្មជាតិបញ្ចូលក្នុងថង់បែបនេះ សម្រាប់តែការដឹកជញ្ជូនផ្លូវជិតតែប៉ុណ្ណោះ។ ប៉ុន្តែក្នុងករណីកូនត្រីត្រូវដឹកជញ្ជូនផ្លូវឆ្ងាយ ចាំបាច់ត្រូវប្រើខ្យល់អុកស៊ីសែន។
- រួចត្រូវត្រៀមកញ្ជេរ ឬជាល ឬ ល្អីឬស្សី ហើយទ្រាប់សំបកបាវ រួចដាក់ថង់កូនត្រីទៅក្នុងកញ្ជេរ ឬជាល ឬ ល្អីឬស្សី ដើម្បីការពារកុំឱ្យថង់ធ្លាយ។

**របៀបបញ្ចូលខ្យល់អុកស៊ីសែនក្នុងថង់ដាក់កូនត្រី**



ដាក់ទឹកមួយភាគបួននៃកម្ពស់ថង់ និងកូនត្រីពូជ ២00ក្បាល | របៀបបញ្ចូលខ្យល់ធម្មជាតិក្នុងថង់ | របៀបចាប់ក្របួចមាត់ថង់ | របៀបចងមាត់ថង់ | ថង់កូនត្រីចងរួច

## របៀបបញ្ចូលខ្យល់អុកស៊ីសែនក្នុងថង់ដាក់កូនត្រី



ដាក់ទឹកមួយភាគបួន នៃកម្ពស់ថង់ | ដាក់កូនត្រីពូជ ៣០០ ក្បាល | ដាក់មាត់ទុយោ ដល់ក្នុងទឹក | របៀបបញ្ចូលខ្យល់ អុកស៊ីសែន | បញ្ចេញខ្យល់ធម្មជាតិពីថង់ រួចបញ្ចូលខ្យល់អុកស៊ីសែន | ដកទុយោ ចេញពីថង់ | ថង់កូនត្រីចងរួច

## ខ. ការដឹកជញ្ជូន ដោយប្រើធុង ឬ ឆ្នាំ

ការដឹកជញ្ជូនរបៀបនេះ អនុវត្តសម្រាប់ដឹកជញ្ជូនតែផ្លូវជិតៗប៉ុណ្ណោះ ។ មុនដំបូងត្រូវដាក់ទឹកក្នុងឆ្នាំង ឬធុង ឱ្យបាន ១ ភាគ ៣នៃធុង ឬឆ្នាំងនោះ រួចដាក់កូនត្រី ។ ដើម្បីកុំឱ្យកូនត្រីលោតចេញពីឆ្នាំង ឬ ធុងត្រូវប្រើស្បៃ ឬ ក្រមា គ្របចងពីលើ ។ យើងអាចរែក ទូល កណ្ដៀត ឬជិះកង់ឌុបកូនត្រីនោះបានយ៉ាងងាយ ។





ប្រភពធនធានចំរុះសំរាប់ចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ
អាងភ្ញាស់ត្រី
កាកសំណល់ផ្ទះបាយ ផេះ
កន្ទក់ ចុងអង្ករ
លាមកសត្វ
រណ្ដៅជីកំប៉ុស
កាកសំណល់បន្លែ
ម្ទេស
រុក្ខជាតិបៃតង
ត្រប់
ត្រី ស្រូវ

រៀបរៀងដោយ : នាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
ឧបត្ថម្ភបោះពុម្ពដោយ : Project Code: 10-PR1-0409

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN

aecid

AIDA
AYUDA, INTERCAMBIO Y DESARROLLO

ព័ត៌មានបន្ថែមសូមទំនាក់ទំនងនាយកដ្ឋានអភិវឌ្ឍន៍វារីវប្បកម្ម នៃរដ្ឋបាលជលផល
អគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៨៣៥ ទូរស័ព្ទ/ទូរសារ ៨៥៥ ២៣ ៩៩៦ ៣៨០
អ៊ីម៉ែល : chinda77@yahoo.com